# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៤

## ជប៉ុនផ្តល់ ១៤១,២៣២ ដុល្លារអាមេរិក ដើម្បី ពង្រឹងប្រព័ន្ធថែទាំសុខភាពបឋម មាតា និងទារក នៅខេត្តកំពង់ចាម



ក្រោមគ្រោងការណ៍នៃ ជំនួយឧបត្ថម្ភឥតសំណង សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ១៤១,២៣២ ដុល្លាអាមេរិក ដល់អង្គការមូលនិធិជប៉ុន ភី-អេជ-ជេ (PHJ)។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះដោយ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកស្រី អ៊ីជិហារ៉ា កាហ្ស៊ូកូ នាយិកា អង្គការមូលនិធិជប៉ុន ភី-អេជ-ជេ (PHJ) ដើម្បីអនុវត្ត “គម្រោងពង្រឹងប្រព័ន្ធ ថែទាំសុខភាពបឋម មាតា និងទារក នៅខេត្តកំពង់ចាម”។

ដើម្បីធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធសេវាថែទាំសុខភាពបឋមនៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម PHJ នឹងចាប់ផ្តើមគម្រោងថ្មីមួយ ហើយនឹងផ្តល់នូវការបណ្តុះបណ្តាលឆ្មប និងរៀបចំសិក្ខាសាលាសម្រាប់បុគ្គលិកមណ្ឌលសុខភាព និងអ្នកស្ម័គ្រចិត្តថែទាំសុខភាពសហគមន៍ ដែលផ្តល់ការផ្សព្វផ្សាយអំពីការលើកកំពស់សុខភាពមាតានិងទារក (MCH) ដល់អ្នកភូមិ និងធ្វើឲ្យមានទំនាក់ទំនងកាន់តែប្រសើរឡើងរវាងអ្នកភូមិនិងមណ្ឌលសុខភាព។ យើងរំពឹងថានៅពេលគម្រោងនេះត្រូវបានបញ្ចប់ ប្រជាជនប្រមាណ ៣២០០០ នាក់នៅក្នុងតំបន់គោលដៅ នឹងអាចអនុវត្តការថែទាំសុខភាពមាតា និងទារក បានជាប់លាប់ ហើយ នឹងអាចលើកកម្ពស់ការយល់ដឹងរបស់ពួកគេអំពីអនាម័យ តាមរយៈគម្រោងនេះ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង២១.៦លាន ដុល្លាអាមេរិកដល់គម្រោងចំនួន ៨០ គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និង សកម្មភាពបោសសំអាតមីន។ គម្រោងនេះគឺជាគម្រោងទី២ តាមរយៈគ្រោងការណ៍នៃជំនួយនេះ សម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៤របស់ជប៉ុន (មេសា ២០១៤ ដល់ មិនា ២០១៥)។





ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០
អ៊ីមែល: eco.jpn@pp.mofa.go.jp
គេហទំព័រ: http://www.kh.emb-japan.go.jp